ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៤០៩/១៦_១០_០៦

សាលដីកា

លេខ:៣៥ ខ /០៣_៤_០៨

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាសាលាឧទ្ធរណ៍ នៅថ្ងៃទី ០៣-៤-២០០៨ ដោយមានសមាសភាព ដូចខាងក្រោមៈ

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១- លោក [redacted] ជាប្រធាន

២- លោក [redacted] ជាចៅក្រម

៣- លោក [redacted] ជាចៅក្រម

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

**១- ជនជាប់ចោទឈ្មោះ**[redacted] **រដ្ឋា ហៅ ម៉ាប់ ហៅ ថា** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរៈជាង ម៉ាស៊ីនត្រជាក់ ទីលំនៅមុនពេលចាប់ខ្លួ[redacted]ណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនៈគ្មាន ចាប់ខ្លួនថ្ងៃទី០៥-៨-០៥. ឃុំខ្លួនថ្ងៃទី១២-៨-០៥ បច្ចុប្បន្ននៅពន្ធនាគារត្រពាំងផ្លុង ម៣ ។

**ត្រូវចោទពីបទៈ** "ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា៦. ២០ នៃច្បាប់ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ ។

**២- ជនជាប់ចោទឈ្មោះ**[redacted]**សុធារុធ ហៅ ទី ហៅ តាប់** ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរៈ ជាងម៉ាស៊ីនត្រជាក់ ទីលំនៅមុនពេលចា[redacted] ក្រុមទី១០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ[redacted] "រ" ម្ដាយឈ្មោះ[redacted] "រ" នៅលីវ ទោសពីមុនៈគ្មាន ចាប់ខ្លួនថ្ងៃទី០៥-៨-២០០៥ ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅពន្ធនាគារត្រពាំងផ្លុង ម៣ ។

**ត្រូវចោទពីបទៈ** "សមគំនិតក្នុងអំពើប្លន់" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា ៦, ៦៩ នៃ ច្បាប់ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និង ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ប៊ូវ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរៈរត់ម៉ូតូឌុប ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេ[redacted]សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០៥-៨-០៥ ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១។

**៤- ជនជាប់ចោទឈ្មោះ** [redacted] ព្រីម ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរៈ ជាងជួសជុលម៉ូតូ ទីលំនៅមុនពេលចាប់ខ្លួន[redacted]ណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី០៥-៨-២០០៥ ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១១។

**ត្រូវចោទពីបទៈ** "ទទួលផលចោរកម្ម" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] សោភា ភេទស្រី អាយុ១៨ឆ្នាំ មុខរបរៈសិស្ស សព្វថ្ងៃរស់នៅ ផ្ទះលេខ៦១០ ផ្លូវ២៧១ ក្រុម៣៧ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ។

-តាមបណ្តឹងឧទ្ធរណ៍លេខ ២៩៣ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **រដ្ឋា**, បណ្តឹងឧទ្ធរណ៍លេខ២៩៦ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **សុធារ៉ុធ**, បណ្តឹងឧទ្ធរណ៍លេខ ១៩៣ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ** និងបណ្តឹងឧទ្ធរណ៍លេខ ១៩០ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ព្រីម** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤៤ "ឃ" ចុះថ្ងៃទី០៩-៣-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ គ្រប់ចំណុចទាំងមូល។

## ដំណើររឿងមានដូចតទៅៈ

តាមពាក្យបណ្តឹងចុះថ្ងៃទី១០-៧-២០០៥ របស់ឈ្មោះ[redacted] សោភា ថាកាលពីថ្ងៃទី១០-៧-២០០៥ ម៉ោង១២កន្លះថ្ងៃត្រង់ ខ្លួនជិះម៉ូតូម៉ាកគប់ សេ៩០ ពណ៌ទឹកប្រាក់ ពាក់ផ្លាកលេខ១A-៣៤១២ ភ្នំពេញ លេខតួ HA ០២- ២១២២៤៥១, លេខម៉ាស៊ីន HA - ០២ E ២០៣៥៨៦៧ ជិះដល់ចំណុចផ្លូវលេខ៤៨៦ សង្កាត់ផ្សារដើមថ្កូវ មានជនល្មើសពីរនាក់ ជិះម៉ូតូម៉ាកគប់ ពណ៌ទឹកប៊ិច មកកៀរខ្លួនម្នាក់អង្គុយពីក្រោយដកកាំភ្លើងម៉ាកមិនស្គាល់ភ្ជង់ខ្លួនឱ្យចុះពីម៉ូតូ រួចវាយកម៉ូតូខ្លួន ជិះទៅតាមផ្លូវ៤៣០ បាត់ ពេលនគរបាលចាប់បានជនល្មើស ឱ្យខ្លួនទៅចង្អុលមុខប៉ូលីសប្រាប់ឈ្មោះ, ខ្លួនមើលស្គាល់ឈ្មោះ[redacted] ភារម្យ នេះដែលយកកាំភ្លើងភ្ជង់ប្លន់យកម៉ូតូ ខ្លួន។ សំណូមពរ ទាមទារថ្លៃម៉ូតូ ១៣០០ដុល្លា, ជំងឺចិត្ត ៣០០ដុល្លា និងផ្តន្ទាទោសជនល្មើសតាមច្បាប់។

**- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៤ "ឃ" ចុះថ្ងៃទី០៩-៣-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :**

១- ផ្តន្ទាទោសលើឈ្មោះ [redacted] **ភារម្យ** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ និង ឈ្មោះ [redacted] **រដ្ឋា** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល០៦ឆ្នាំ "ប្រាំមួយឆ្នាំ" សំរាប់បទប្លន់ និង០១ឆ្នាំ "មួយឆ្នាំ" សំរាប់បទៈប្រើប្រាស់អាវុធខុសច្បាប់ និងម្នាក់ៗ ពិន័យជាប្រាក់ ៥០ម៉ឺនរៀលចូលថវិការដ្ឋ គិតបន្តពីសាលក្រមលេខ៤២ "ឃ" ចុះថ្ងៃទី០៩-

៣-២០០៦ របស់តុលាការក្រុងភ្នំពេញ ចប់សព្វគ្រប់ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០-៧-២០០៥ តាមមាត្រា៦, ២០ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

២- ផ្តន្ទាទោសលើឈ្មោះ [redacted] សុធាវុធ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ "ប្រាំមួយឆ្នាំ" គិតបន្តចាប់ពីសាលក្រមលេខ៤២ "ឃ" ចុះថ្ងៃទី០៩-៣-២០០៦ របស់តុលាការក្រុងភ្នំពេញ ពីបទសមគំនិតក្នុងអំពើ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា ៦, ៦៩ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- - លើកលែងចោទប្រកាន់លើឈ្មោះ [redacted] សុវណ្ណ, [redacted] ព្រឹម និងឈ្មោះ [redacted] គីមស្រ៊ី ពីបទ សមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា៦, ៦៩ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសបទឧក្រិដ្ឋ និង ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- ផ្តន្ទាទោសលើឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់០១ឆ្នាំ "មួយឆ្នាំ" គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១២-៨-២០០៥ សំរាប់ឈ្មោះ [redacted] សុវណ្ណ និងថ្ងៃទី១២-៨-២០០៥ សំរាប់ឈ្មោះ ប៉ាល់ ព្រឹម ពីបទទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ផ្តន្ទាទោសលើឈ្មោះ [redacted] គីមស្រ៊ី ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ "មួយឆ្នាំ" តែទោសព្យួរសាកល្បងរយៈពេល៥ឆ្នាំ គិតពីថ្ងៃសាលក្រមស្ថាពរតទៅ ពីបទទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ តាមមាត្រា ៥១, ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- បង្គាប់ឱ្យឈ្មោះ [redacted] ភារម្យ, [redacted] វដ្ឋា, [redacted] សុធាវុធ, [redacted] សុវណ្ណ, [redacted] ព្រឹម និង [redacted] គីមស្រ៊ី រួមគ្នាសងប្រាក់ថ្លៃ ម៉ូតូ និងជំងឺចិត្តសរុប ១៣០០ដុល្លា ទោឱ្យជនរងគ្រោះឈ្មោះ សាម សោភា គិតពីថ្ងៃសាលក្រមស្ថាពរតទៅ ។ បើឈ្មោះទាំង ប្រាំមួយនាក់ខាងលើរឹងរូសពុំព្រមសងប្រាក់នេះទេ ត្រូវដាក់គុកតាមច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៦- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩-៣-២០០៦ ប្រកាសជាសាធារណៈនៅថ្ងៃទី០៥-៥-២០០៦ ចំពោះមុខជនជាប់ចោទ [redacted] **ភារម្យ** [redacted] **វដ្ឋា**, [redacted] សុធាវុធ, [redacted] **សុវណ្ណ និង** [redacted] **ព្រឹម** ចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ [redacted] **គីមស្រ៊ី និងជនរងគ្រោះ** សំរេចទុកសិទ្ធិឱ្យប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៥៣ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **វដ្ឋា**, បណ្តឹងឧទ្ធរណ៍លេខ២៥៦ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុធាវុធ**, បណ្តឹងឧទ្ធរណ៍លេខ ១៩៣ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ** និងបណ្តឹងឧទ្ធរណ៍លេខ ១៩០ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ព្រឹម** ថ្វីមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤៤ "ឃ" ចុះថ្ងៃទី០៩-៣-២០០៦ របស់សាលា ដំបូងក្រុងភ្នំពេញ គ្រប់ចំណុចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងចុះថ្ងៃទី០៨-១១-២០០៧ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍រឿង

**- ជនជាប់ចោទឈ្មោះ** [redacted] សុវណ្ណ **ឆ្លើយថា:** ខ្លួនអត់បានទិញម៉ូតូម៉ាកគុប៩០ ពី [redacted] ភារម្យ ទេ។ ខ្លួនបានទិញម៉ូតូម៉ាកគុប៧០ រាងជំនុំពី [redacted] ភារម្យ ក្នុងតម្លៃជាងបួនរយដុល្លាអាមេរិក ពេលខ្លួនទិញខ្លួនអត់ដឹងថាជាម៉ូតូប្លន់គេទេ គេធ្វើបណ្ណ័ធានាឱ្យខ្លួនទិញសំរាប់ជិះផ្ទាល់ តែ [redacted] ព្រឹម បានសុំទិញឱ្យខ្លួនចំណេញ ២០ដុល្លា ខ្លួនក៏លក់ឱ្យគាត់ទៅ ។ សំណូមពរ សុំជួយលើកលែងចោទប្រកាន់ដល់រូបខ្លួន ។

**- ជនជាប់ចោទឈ្មោះ** [redacted] **ព្រឹម ឆ្លើយថា:** ខ្លួនបានទទួលទិញម៉ូតូម៉ាកគុប៧០ ពី [redacted] សុវណ្ណ មានសំបុត្រធានាត្រឹមត្រូវ ខ្លួនមិនដឹងថា ជាម៉ូតូប្លន់គេមកទេ ខ្លួនទិញក្នុងតម្លៃជាងបួនរយ សំណូមពរ សុំលើកលែងចោទប្រកាន់ដល់រូបខ្លួន ។

**- ជនជាប់ចោទឈ្មោះ** [redacted] **ភារម្យ ឆ្លើយថា:** ខ្លួនស្គាល់ [redacted] សុវណ្ណ ដោយធ្លាប់រៀនជាមួយគ្នា ឯឈ្មោះ [redacted] ព្រឹម ខ្លួនមិនស្គាល់ទេ។ នៅថ្ងៃទី១០-៧-២០០៥ ខ្លួន និង [redacted] សុធារុធ ជាអ្នកប្រព្រឹត្ត, ឯឈ្មោះ [redacted] រដ្ឋា មិនបានចូលរួមទេ។ ខ្លួនបានទូស័ព្ទហៅ [redacted] សុធារុធ មកប្លន់ តែ [redacted] រដ្ឋា ខ្លួនបានហៅទៅស៊ីផឹកប៉ុណ្ណោះ, ពេលធ្វើសកម្មភាពខ្លួនខ្ចីកាំភ្លើងម៉ាកអ៊ូឡូ ពីឈ្មោះ [redacted] ដារ៉ារិទ្ធ ហើយម៉ូតូដែលប្លន់បានខ្លួនយកទៅលក់ឱ្យ [redacted] សុវណ្ណ ដោយប្រាប់ថាជាម៉ូតូរបស់ខ្លួន ក្នុងតម្លៃជាងបួនរយដុល្លា។ សំណូមពរ សុំបន្ធូរបន្ថយទោសដល់ខ្លួនផង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមតុលាការក្រុងភ្នំពេញដែលសម្រេចផ្តន្ទាទោសក្នុងកំរិតអប្បបរិមានៃទោសនេះ ទុកជាត្រឹមត្រូវ និងបានការតទៅ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

- ក្នុងរឿងនេះ ពេលសវនាការកូនក្តីខ្លួន [redacted] ភារម្យ បានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសនៅថ្ងៃទី១០-៧-២០០៥ មែន ហើយចម្លើយនេះបានបញ្ជាក់តាំងពីនៅតុលាការក្រុងម្លេះ តែតុលាការថ្នាក់ក្រោម នៅតែដាក់ទណ្ឌកម្មដល់កូនក្តីខ្លួន [redacted] សុវណ្ណ និង [redacted] ព្រឹម ទៀត ទើបកូនក្តីខ្លួនប្តឹងឧទ្ធរណ៍មក, ហើយរាល់ការទិញម៉ូតូ ឬ ឡានដែលអត់ពន្ធមិនមែនបញ្ជាក់ថាកូនក្តីខ្លួនប្រព្រឹត្តបទល្មើសនោះទេ សូមលោកប្រធានមេត្តាលើកលែងទោសចោទប្រកាន់ដល់កូនក្តីខ្លួន [redacted] សុវណ្ណ និង [redacted] ព្រឹម និង សុំបន្ធូរបន្ថយទោសដល់ [redacted] ភារម្យ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

# សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

- យល់ឃើញថា: បណ្តឹងឧទ្ធរណ៍លេខ ២៥៣ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា. បណ្តឹងឧទ្ធរណ៍លេខ២៥៦ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សុធាវុធ. បណ្តឹងឧទ្ធរណ៍លេខ ១៩៣ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ និងបណ្តឹងឧទ្ធរណ៍លេខ ១៩០ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ព្រឹ: ធ្វើឡើងនៅក្នុងកំណត់ច្បាប់.

- យល់ឃើញថា: ពាក្យចុះថ្ងៃទី - -២០០៨ សុំឱ្យទទួលស្គាល់ជាមេធាវីការពារជនជាប់ចោទ របស់លោកមេធាវី [redacted] ទ្រី ធ្វើឡើងត្រឹមត្រូវតាមច្បាប់.

- យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] ភារម្យ និង [redacted] សុធាវុធ ឆ្លើយសារភាពថា នៅថ្ងៃទី ១០-៧-២០០៥ វេលាម៉ោង១២ថ្ងៃត្រង់ ខ្លួន និង [redacted] សុធាវុធ ជិះមូតូគុប៥០ បានប្លន់មូតូម៉ាកគុប ពីនារីម្នាក់ ខ្លួនជាអ្នកភ្ជង់ដោយកាំភ្លើងខ្លីម៉ាករូទ្ យកទៅលក់ឱ្យ [redacted] សុវណ្ណ. នៅថ្ងៃទី២៧-៧-២០០៥ វេលាម៉ោង០១ថ្ងៃ ខ្លួន និង [redacted] សុធាវុធ ប្លន់បានម៉ូតូស្លាស់ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] វដ្ឋា បានឆ្លើយនៅនគរបាលថា កាលពីថ្ងៃទី១០-៧-២០០៥ វេលាម៉ោង១២ និង ៣០នាទី [redacted] ភារម្យ ទូរស័ព្ទហៅខ្លួនឱ្យទៅស៊ីផឹក ទៅ ជាមួយ [redacted] សុធាវុធ នៅព្រែកលាប រួចបបួលខ្លួនទៅប្លន់ ហើយ [redacted] សុធាវុធ ប្រគល់ម៉ូតូវាឱ្យខ្លួន ឌុប [redacted] ភារម្យ ទៅដល់សង្កាត់ផ្សារដើមថ្កូវ [redacted] ភារម្យ ភ្ជង់ប្លន់ម៉ូតូស្រីម្នាក់ លុះម៉ោង១៦ [redacted] ភារម្យ យកលុយឱ្យខ្លួន៧០ដុល្លាអាមេរិក ហើយវាប្រាប់ថា ម៉ូតូលក់ឱ្យព្រំ សុវណ្ណ បាន៣០០ដុល្លា. ឱ្យ [redacted] សុធាវុធ ២០ដុល្លាអាមេរិក.

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ថា នៅថ្ងៃទី១០-៧-២០០៥ [redacted] ភារម្យ ទូរស័ព្ទហៅខ្លួនឱ្យទិញម៉ូតូដែលវាប្លន់បាន. ខ្លួនទិញបាន០២ថ្ងៃ លក់ឱ្យឈ្មោះ [redacted] ព្រឹម ។ ឯឈ្មោះ [redacted] ព្រឹម ថាខ្លួនបានទិញម៉ូតូពី [redacted] សុវណ្ណ បានពីរដងគឺថ្ងៃទី០២-៦-២០០៥ ទិញបានម៉ូតូម៉ាកវេវ អាលីហ្វា. ថ្ងៃទី១២-៧-២០០៥ ទិញបានម៉ូតូគុប៧០ ។

**-យល់ឃើញថា:** មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] ភារម្យ, [redacted] សុធាវុធ និង [redacted] វដ្ឋា ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

**-យល់ឃើញថា:** មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ, [redacted] គឹមស្រ៊ី និង [redacted] ព្រឹម ពីបទ ទទួលផលចោរកម្ម** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៧-២០០៥ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**-យល់ឃើញថា:** សាលក្រមព្រហ្មទណ្ឌលេខ ៤៤ "ឈ" ចុះថ្ងៃទី០៩-៣-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ លើកលែងតែវិធានអនុវត្តដាក់គុកបង្ខំរូបកាយ គួរលើកចោល.

## **សេចក្តីដូចនេះវិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៥៣ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា. បណ្តឹងឧទ្ធរណ៍លេខ២៥៦ ចុះថ្ងៃទី០៥-៧-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុធាវុធ**. បណ្តឹងឧទ្ធរណ៍លេខ ១៩៣ ចុះថ្ងៃទី២៤-៥-២០០៦ របស់ជន ជាប់ចោទឈ្មោះ [redacted] **សុវណ្ណ** និងបណ្តឹងឧទ្ធរណ៍លេខ ១៩០ ចុះថ្ងៃទី ២៤-៥-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ព្រឹម **ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់** ។

២- ទទួលស្គាល់លោក [redacted] ទ្រី ជាមេធាវីការពារជនជាប់ចោទ

៣- តម្កល់សាលក្រមលេខ ៤៤ "ឍ" ចុះថ្ងៃទី០៩-៣-២០០៦ របស់សាលាដំបូងភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែលើកចោលនូវវិធានអនុវត្តដាក់គុកបង្ខំរូបកាយ ក្រៅពីនេះទុកនៅដដែល ។

៤- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** [redacted] រដ្ឋា និង [redacted] សុធាវុធ.

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ភារម្យ**. [redacted] **សុវណ្ណ** និង [redacted] **ព្រឹម** និង មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **រដ្ឋា** និង [redacted] សុធាវុធ . ដើមបណ្តឹងរដ្ឋប្បវេណី. បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះ ចូលជាស្ថាពរមានអានុភាពអនុវត្តតែទៅលើឈ្មោះ [redacted] ភារម្យ និងឈ្មោះ [redacted] ព្រឹម ប៉ុណ្ណោះ ក្រៅពីនេះមិនទាន់មានអានុភាពអនុវត្តឡើយ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទទួលបង្គាប់បញ្ជាមកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.................................................................................................................

| | |
| --- | --- |
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ |
| | ក្រឡាបញ្ជី |
| [redacted] | [redacted] |